**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី

# សេចក្តីជូនព័ត៌មាន

តបតាមការអញ្ជើញរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លោកជំទាវល្វីស មូស៊ីគីវ៉ាបូ (Louise Mushikiwabo) អគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) នឹងដឹកនាំគណៈប្រតិភូអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅ**កម្ពុជា** ពីថ្ងៃទី **២ ដល់ទី ៥ ខែធ្នូ ឆ្នាំ** ២០១៩ ។

នេះគឺជាទស្សនកិច្ចផ្លូវការលើកទីមួយរបស់**លោកជំទាវ ល្វីស មូស៊ីគីវ៉ាបូ** ក្នុងគោលដៅពង្រឹងទំនាក់ទំនងរវាងកម្ពុជា និងអង្គការ OIF បន្ទាប់ពីលោកជំទាវចូលកាន់តំណែងជា**អគ្គលេខាធិការ** កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩មក ។ ទស្សនកិច្ចផ្លូវការនេះ ប្រព្រឹត្តទៅក្នុងពេលដំណាលគ្នានឹង**មហាសន្និបាតអភិបាលក្រុងនិយាយភាសាបារាំង**(AIMF) នៅរាជធានីភ្នំពេញ ដែលជាព្រឹត្តិការណ៍ហ្វ្រង់កូហ្វូនដ៏សំខាន់មួយដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ ហើយដែលលោកជំទាវនឹងអញ្ជើញចូលរួមផងដែរ។

នៅក្នុងអំឡុងពេលនៃទស្សនកិច្ចផ្លូវការនេះ នៅ**រាជធានីភ្នំពេញ** លោកជំទាវអគ្គលេខាធិការនឹងចូលក្រាបថ្វាយបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជួបសម្តែងការគួរសមចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងពិភាក្សាការងារជាមួយ **ឯកឧត្តម សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

នៅខេត្តសៀមរាប លោកជំទាវអគ្គលេខាធិការនឹងទទួលស្វាគមន៍ដោយ**ឯកឧត្តម អភិបាលខេត្តសៀមរាប** អញ្ជើញទស្សនាប្រាង្គ**ប្រាសាទអង្គរ** ចូលរួមក្នុង**សិក្ខាសាលា**តំបន់ស្តីពីសកម្មភាពស្រាវជ្រាវ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលតំបន់ហ្វ្រង់កូហ្វូនអាស៊ី-ប៉ាស៊ីហ្វិក (CREFAP) និងក្រសួងអប់រំ យុវជន និង កីឡា ផងដែរ និងទស្សនាថ្នាក់រៀនពីភាសានៃសាលាបឋមសិក្សាវត្តបូ ផងដែរ ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

អង្គការ OIF ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧០ ដោយបិតាស្ថាបិកចំនួន ៤ រូប គឺ **ឯកឧត្តម** Léopold Sédar Senghor ប្រមុខរដ្ឋប្រទេសសេណេហ្គាល់ **ឯកឧត្តម** Habib Bourguiba ប្រមុខរដ្ឋប្រទេសទុយនីស៊ី **ឯកឧត្តម** Hamani Diori ប្រមុខរដ្ឋប្រទេសនីហ្សេ និង **ព្រះករុណា ព្រះបរមរតនកោដ្ឋ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** នៃប្រទេសកម្ពុជា ។ នាពេលបច្ចុប្បន្ននេះ អង្គការ OIF បានក្លាយជាអង្គការអន្តររដ្ឋាភិបាលដ៏ធំមួយនៅក្នុងពិភពលោក (បន្ទាប់ពីអង្គការសហប្រជាជាតិ) មានរដ្ឋនិងរដ្ឋាភិបាលសមាជិកសរុបចំនួន ៨៨ (សមាជិកពេញសិទ្ធិចំនួន ៥៤ មិនពេញសិទ្ធិ ចំនួន ៧ និងសមាជិកសង្កេតការណ៍ចំនួន ២៧)។

ថ្ងៃ ច័ន្ទ ៦ កើត ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩